ព្រះរាជាណាចក្រកម្ពុជា

ជាតិ   សាសនា   ព្រះមហាក្សត្រ

# ច្បាប់

## ស្ដីអំពី

# ហិរញ្ញវត្ថុសំរាប់ឆ្នាំ១៩៩៤

# ច្បាប់
# ស្ដីអំពី
# ហិរញ្ញវត្ថុសំរាប់ឆ្នាំ១៩៩៤

## ភាគទីមួយ

## ការរៀបចំច្បាប់ហិរញ្ញវត្ថុ

## ជំពូកទីមួយ

# បទបញ្ញត្តិទូទៅ

មាត្រា ១- ត្រូវបានអនុញ្ញាតក្នុងឆ្នាំ ១៩៩៤ នូវការប្រមូលពន្ធចូលថវិការទូទៅរបស់រដ្ឋ នូវពន្ធដារ អាករផលទុន និងចំណូលនានា រួមទាំងការសំរេចឱ្យអំណោយ មូលនិធិបរិភោគ និង ធនធានបានមកពីការខ្ចីបុល ដែលបានគ្រោងទុកនៅតារាង "ក" ក្នុងផ្នែកទី ២ នៃច្បាប់នេះ ក្នុងចំនួនទឹកប្រាក់សរុប ៨៨៩.៦០០ លានរៀល ដែលត្រូវបែងចែកដូចតទៅ ៖

- ចំណូលជាប្រចាំ "ចំណូលប្រក្រតី" ៤៦០.០០០ លានរៀល
- ចំណូលជាមូលធន ៤២៩.៦០០ លានរៀល

មាត្រា ២- ចំនួនទឹកប្រាក់ជាអតិបរិមា នៃឥណទានសំរាប់ចំណាយក្នុងថវិការទូទៅរបស់រដ្ឋ សំរាប់ឆ្នាំ ១៩៩៤ ត្រូវបានកំណត់ស្មើនឹង ៨៨៩.៦០០ លានរៀល នឹងត្រូវបែងចែកដូចតទៅ ៖

- ចំណាយជាប្រចាំ "ចំណាយប្រក្រតី" ៥៧៧.៦០០ លានរៀល
- ចំណាយជាមូលធន ៣១២.០០០ លានរៀល

មាត្រា ៣- ហាមអស់លោក ប្រធានស្ថាប័នរដ្ឋបាល និងអ្នកបញ្ជាចំណាយ ជាសំខាន់ ក៏ដូចជាអ្នកបញ្ជាចំណាយ ដែលបានទទួលការប្រគល់សិទ្ធិក្នុងការវិះរកវិធានការទាំងឡាយដែលនាំឱ្យបង្កើនចំណាយ ដែលអាចកត់ត្រាទៅក្នុងឥណទានថវិកាទូទៅរបស់រដ្ឋ ហើយដែលពុំមែនបានចេញមកពីការអនុវត្តច្បាប់ ក្រឹត្យ និង បទបញ្ជាមានពីមុនមក ។

អស់លោកប្រធានស្ថាប័នរដ្ឋបាល និងអ្នកបញ្ជាចំណាយជាសំខាន់ ក៏ដូចជាអ្នកបញ្ជាចំណាយ ដែលបានប្រគល់សិទ្ធ នឹងត្រូវទទួលខុសត្រូវដោយផ្ទាល់ខ្លួន ចំពោះការសំរេចទាំងឡាយណាដែលផ្ទុយនឹងបទបញ្ញត្តិខាងលើនេះ ។

មាត្រា ៤- ចំនួនទឹកប្រាក់ជាអតិបរិមានៃឥណទាន សំរាប់ចំណាយជាប្រចាំរបស់រដ្ឋសំរាប់ឆ្នាំ ១៩៩៤ ត្រូវបានកំណត់ស្មើនឹង ៥៧៧.៦០០ លានរៀល ។ ឥណទាននេះត្រូវធ្វើការបែងចែកទៅតាមក្រសួងនីមួយៗ និងស្ថាប័នសាធារណៈប្រហាក់ប្រហែលនីមួយៗ និងទៅតាមប្រភេទដូចមានចែងក្នុងតារាង "ខ" ក្នុងភាគទី ២ នៃច្បាប់នេះ ។

មាត្រា ៥_ ចំនួនទឹកប្រាក់ឥណទាន សំរាប់កម្មវិធីរបស់រដ្ឋត្រូវបានកំណត់សំរាប់ឆ្នាំ ១៩៩៤_១៩៩៦ គឺ ១.៣១៦.០៧០ លានរៀល ។

ក្នុងលក្ខខ័ណ្ឌបណ្តោះអាសន្ន ក្នុងដំណាក់កាលបច្ចុប្បន្ន នៃដំណើការអភិវឌ្ឍន៍របស់ព្រះរាជាណាចក្រកម្ពុជា ឥណទានសំរាប់កម្មវិធី ត្រូវបានកំណត់ដោយយកលើមូលដ្ឋាននៃការចាំងស្មានលើពាក្យសន្យាផ្តល់ជំនួយពីបរទេស ។

ឥណទានទាំងនេះត្រូវបែងចែកទៅតាមក្រសួងនីមួយៗឬតាមកម្មវិធីនីមួយៗឬគំរោងការនីមួយៗ ដូចមានចែងក្នុងតារាង "ក" ក្នុងភាគទី ២ នៃច្បាប់នេះ ។

មាត្រា ៦_ ចំនួនទឹកប្រាក់ជាអតិបរិមានៃឥណទានសំរាប់ចំណាយ (CREDITS D'ENGAGEMENT) និងឥណទានសំរាប់ទូទាត់ (CREDITS DE PAIEMENT) នីមួយ ៗ សំរាប់ចំណាយជាមូលធននៃថវិការរដ្ឋសំរាប់ឆ្នាំ ១៩៩៤ ត្រូវបានកំណត់ ដូចតទៅ ៖

_ឥណទានសំរាប់ធានាចំណាយ ៤៤៨.០៧៨ លានរៀល

_ឥណទានសំរាប់ទូទាត់ចំណាយ ៣១២.០០០ លានរៀល

ឥណទានទាំងអស់នេះត្រូវបានបែងចែកទៅតាមក្រសួង និងស្ថាប័នសាធារណៈប្រហាក់ប្រហែលនីមួយ ៗ និងតាមជំពូកថវិកានីមួយ ៗ ដូចមានចែងក្នុងតារាង "ឃ" ក្នុងភាគទី ២ នៃច្បាប់នេះ ។

មាត្រា ៧_ ចំនួនក្របខ័ណ្ឌមន្ត្រីរាជការ របស់រដ្ឋបាលស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ក្រសួង និង ស្ថាប័នសាធារណៈប្រហាក់ប្រហែលនានា ត្រូវបានកំណត់សំរាប់ឆ្នាំ ១៩៩៤ ស្មើនឹង ១៤៨.៨៧៣ កន្លែង ។

ចំនួនក្របខ័ណ្ឌទាំងនេះត្រូវបែងចែកតាមក្រសួង និងស្ថាប័នសាធារណៈប្រហាក់ប្រហែលនានា ដូចមានចែងក្នុងតារាង "ង" ក្នុងភាគទី ២ នៃច្បាប់នេះ ។

# ជំពូកទី ២

## អំពីចំណូលពន្ធដារ និង ពន្ធគយ

## ពន្ធលើប្រាក់ចំណេញ

### ផ្នែកទី I

### បញ្ញត្តិទូទៅ

មាត្រា ៨_ ត្រូវបង្កើតពន្ធប្រចាំឆ្នាំ លើប្រាក់ចំណេញខាងឧស្សាហកម្ម សិប្បកម្ម ពាណិជ្ជកម្ម សេវាកម្ម ដោយរាប់បញ្ចូលទាំងអាជីវកម្មព្រៃឈើ អណ្តូងរ៉ែ និង នេសាទ ដើម្បីជាប្រយោជន៍ដល់ថវិការដ្ឋ ។

មាត្រា ៩_ ពន្ធនេះត្រូវកំណត់លើប្រាក់ចំណេញ ដែលសំរេចដោយរូបវន្តបុគ្គល ឬនីតិបុគ្គលក្នុងព្រះរាជាណាចក្រកម្ពុជា

មាត្រា ១០_ ពន្ធនេះកំណត់

_នៅគ្រឹះស្ថានអាជីវកម្មជាគោលដើម បើមានគ្រឹះស្ថានមួយ ឬច្រើន ។

_នៅទីស្នាក់ការរបស់ក្រុមហ៊ុន ប៉ុន្តែអង្គការពន្ធមានកំណត់កន្លែងយកពន្ធនៅកន្លែងចាត់ការជាក់លាក់

_នៅទីកន្លែងដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បើអ្នកជាប់ពន្ធមានសកម្មភាពអាជីវកម្ម ឬមានសារប្រយោជន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជាហើយគ្មានទីស្នាក់ការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា ១១_ ការកំណត់ពន្ធលើប្រាក់ចំណេញត្រូវអនុវត្តតាមរបបពិតប្រាកដ ឬតាមរបបម៉ៅការ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ កំណត់តាមប្រកាសអំពីបែបបទកំណត់ពន្ធនេះ ដោយតាមមុខរបរ ករិតផលរបរ និងទ្រង់ទ្រាយអាជីវកម្ម ។

### ផ្នែកទី II

## ប្រាក់ចំណេញជាប់ពន្ធ និងអត្រាពន្ធ

មាត្រា ១២_ ពន្ធនេះត្រូវគិតលើប្រាក់ចំណេញ ដែលគិតចេញពីលទ្ធផលនៃតុល្យការសំរេចបានក្នុងឆ្នាំកន្លងទៅ ឬក្នុងរយៈពេល ១២ ខែ ប្រសិនបើរយៈពេលនេះពុំសមស្របទៅតាមឆ្នាំធម្មតា ។

បើប្រសិនជាពុំមានតុល្យការណាមួយបានបញ្ឈប់ក្នុងកំឡុងនៃឆ្នាំណាមួយទេនោះ ពន្ធដែលត្រូវបង់សំរាប់ឆ្នាំជាបន្ទាប់ត្រូវគិតយកលើប្រាក់ចំណេញក្នុងរយៈវេលាដែលកន្លងទៅ ចាប់តាំងពីថ្ងៃចុងរយៈពេលជាប់ពន្ធដែលកន្លងហួសទៅនោះ ។ ចំពោះសហគ្រាសថ្មី ត្រូវគិតចាប់ពីថ្ងៃដែលផ្តើមធ្វើប្រតិបត្តិការមកទល់នឹងថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំដែលត្រូវគិតពន្ធ ។

កាលបើមានធ្វើតុល្យការជាច្រើនដង ៗគ្នា ក្នុងកំឡុងនៃឆ្នាំមួយដែលនោះ លទ្ធផលនៃតុល្យការទាំងឡាយនេះត្រូវបូករួមគ្នាធ្វើជាមូលដ្ឋាននៃពន្ធ ដែលត្រូវបង់សំរាប់ឆ្នាំតទៅ ។

មាត្រា ១៣ ប្រាក់ចំណេញជាប់ពន្ធ គឺជាប្រាក់ចំណេញសុទ្ធ បានមកពីលទ្ធផលទាំងអស់ នៃប្រតិបត្តិការគ្រប់ប្រភេទ របស់សហគ្រាសទាំងឡាយដែលសំរេចបាន រួមទាំងតំលៃលើសបានកមកពីការលក់ភាគនានានៃទ្រព្យសកម្ម ពេលកំពុងធ្វើអាជីវកម្ម ឬ នៅពេលបញ្ចប់អាជីវកម្មក្តី ។

មាត្រា ១៤_ ប្រាក់ចំណេញជាប់ពន្ធបង្កើតចេញបានដោយអំពីចំនួនលើសនៃផលដុល ដែលសំរេចបានអាស្រ័យដោយមានការចំណាយ ដើម្បីនាំមកវិញ និងរក្សាទុកនូវផលចំណេញ ។

មាត្រា ១៥_ ត្រូវបានអនុញ្ញាតិឱ្យកាត់ចេញ ៖

១_សោហ៊ុយទូទៅគ្រប់ប្រភេទ ចំណាយខាងបុគ្គលិក និងឈ្នួលកម្មករ ថ្លៃឈ្នួលអចលនៈវត្ថុ ដែលសហគ្រាសបានជួល ដើម្បីធ្វើអាជីវកម្ម ។

២_រំលស់ដែលសហគ្រាសបានធ្វើដោយត្រឹមត្រូវ និងពិតប្រាកដ

៣_ការប្រាក់ទាំងឡាយ ដែលត្រូវបានទៅអ្នកចូលហ៊ុន ដោយគិតតែលើចំនួនប្រាក់ដែលលើសអំពីចំណែកទុនរបស់ខ្លួនប៉ុណ្ណោះ

៤_ពន្ធទាំងឡាយដែលជាបន្ទុករបស់សហគ្រាស ហើយដែលត្រូវប្រមូលក្នុងកំឡុងការិយបរិច្ឆេទ លើកលែងតែប្រាក់ពន្ធបន្ថែម និងប្រាក់ពិន័យគ្រប់ប្រភេទ ។

៥_សោហ៊ុយធ្វើដំណើរទាំងទៅទាំងមក ព្រមទាំងសោហ៊ុយសំណាក់នៅបរទេសដែលនាយកសហគ្រាសឬអ្នកតំណាងខ្លួនបានចំណាយ ប៉ុន្តែលុះណាដំណើរនោះត្រូវបានធ្វើ ដើម្បីជាប្រយោជន៍ដល់សហគ្រាស ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកំណត់បញ្ជាក់ពីបែបបទនៃការអនុញ្ញាតឱ្យកាត់ចេញខាងលើនេះ។

មាត្រា ១៦_ ពុំត្រូវបានអនុញ្ញាតឱ្យកាត់ចេញ ៖

១_ការប្រាក់នៃដើមទុនដែលជាប់ប្រើការ (វៀរលែងតែដើមទុននេះបានមកពីខ្ចីគេ)

២_ចំនួនប្រាក់ដែលទុកសំរាប់ធ្វើជាប្រាក់បំរុង ឬសវិធានធន ។ ប៉ុន្តែសវិធានធនទាំងនេះអាចឱ្យរួចពន្ធបានកាលបើសំរាប់ជួសជុលនូវការខូចខាត ឬបន្ទុកដែលមានភាពជាក់ច្បាស់ ហើយបានចុះលេខក្នុងការិយបរិច្ឆេទ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំណត់អំពីបែបបទអនុវត្តការកាត់ចេញនេះ ។

៣_សោហ៊ុយចំណាយផ្ទាល់ខ្លួនរបស់អាជីវករ

មាត្រា ១៧_ ចំពោះក្រុមហ៊ុនដែលទទួលខុសត្រូវមានទំហំសីមា ប្រាក់តំលៃការដែលបើកឱ្យអ្នកចូលហ៊ុនដែលជាអ្នកចាត់ការហើយ ដែលដាក់ចូលទៅក្នុងប្រាក់សោហ៊ុយ និងជាបន្ទុកនោះ ពុំត្រូវអនុញ្ញាតឱ្យកាត់ចេញទេ បើកាលណាភាគច្រើននៃចំណែកហ៊ុនជារបស់អ្នកចូលហ៊ុន ដែលជាអ្នកចាត់ការ ។

ដើម្បីអនុវត្តនូវបទបញ្ញាត្តិនេះ អ្នកចាត់ការទាំងឡាយដែលពុំមែនជាអ្នកចូលហ៊ុន ត្រូវចាត់ទុកថាជាអ្នកចូលហ៊ុនដែរ បើកាលណាសហព័ទ្ធ ឬកូនរបស់ខ្លួនដែលពុំទាន់បានរួចពីអាណាព្យាបាល មានឋានៈជាអ្នកចូលហ៊ុន ក្នុងករណីនេះក៏ដូចជាករណីដែលអ្នកចាត់ការជាអ្នកចូលហ៊ុនដែរ ត្រូវចាត់ទុកជារបស់អ្នកចាត់ការបណ្តាភាគហ៊ុនដែលជាកម្មសិទ្ធិ ឬសិទ្ធិអាស្រ័យផលរបស់កូនមិនទាន់ចាកផុតពីអាណាព្យាបាល និងសហព័ទ្ធរបស់ខ្លួន ។

កាលបើមានធ្វើតុល្យការជាច្រើនដង ។ក្នុងកំឡុងនៃឆ្នាំមួយដែលនោះ លទ្ធផលនៃតុល្យការទាំងឡាយនេះត្រូវបូករួមគ្នាធ្វើជាមូលដ្ឋាននៃពន្ធ ដែលត្រូវបង់សំរាប់ឆ្នាំតទៅ ។

មាត្រា ១៣_ ប្រាក់ចំណេញជាប់ពន្ធ គឺជាប្រាក់ចំណេញសុទ្ធ បានមកពីលទ្ធផលទាំងអស់ នៃប្រតិបត្តិការគ្រប់ប្រភេទរបស់សហគ្រាសទាំងឡាយដែលសំរេចបាន រួមទាំងតំលៃលើសបានកមពីការលក់ភាគនានានៃទ្រព្យសកម្មពេលកំពុងធ្វើអាជីវកម្ម ឬ នៅពេលបញ្ចប់អាជីវកម្មក្តី ។

មាត្រា ១៤_ ប្រាក់ចំណេញជាប់ពន្ធបង្កើតចេញបានដោយអំពីចំនួនលើសនៃផលដុល ដែលសំរេចបានអាស្រ័យដោយមានការចំណាយ ដើម្បីនាំមកវិញ និងរក្សាទុកនូវផលចំណេញ ។

មាត្រា ១៥_ ត្រូវបានអនុញ្ញាត្តិឱ្យកាត់ចេញ ៖

១_ សោហ៊ុយទូទៅគ្រប់ប្រភេទ ចំណាយខាងបុគ្គលិក និងឈ្នួលកម្មករ ថ្លៃឈ្នួលអចលនវត្ថុ ដែលសហគ្រាសបានជួល ដើម្បីធ្វើអាជីវកម្ម ។

២_ រំលស់ដែលសហគ្រាសបានធ្វើដោយត្រឹមត្រូវ និងពិតប្រាកដ

៣_ ការប្រាក់ទាំងឡាយ ដែលត្រូវបានទៅអ្នកចូលហ៊ុន ដោយគិតតែលើចំនួនប្រាក់ដែលលើសអំពីចំណែកទុនរបស់ខ្លួនប៉ុណ្ណោះ

៤_ ពន្ធទាំងឡាយដែលជាបន្ទុករបស់សហគ្រាស ហើយដែលត្រូវប្រមូលក្នុងកំឡុងការិយបរិច្ឆេទ លើកលែងតែប្រាក់ពន្ធបន្ថែម និងប្រាក់ពិន័យគ្រប់ប្រភេទ ។

៥_ សោហ៊ុយធ្វើដំណើរទាំងទៅទាំងមក ព្រមទាំងសោហ៊ុយសំណាក់នៅបរទេសដែលនាយកសហគ្រាសឬអ្នកតំណាងខ្លួនបានចំណាយ ប៉ុន្តែលុះណាដំណើរនោះត្រូវបានធ្វើ ដើម្បីជាប្រយោជន៍ដល់សហគ្រាស ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកំណត់បញ្ជាក់អំពីបែបបទនៃការអនុញ្ញាតឱ្យកាត់ចេញខាងលើនេះ។

មាត្រា ១៦_ ពុំត្រូវបានអនុញ្ញាតឱ្យកាត់ចេញ ៖

១_ ការប្រាក់នៃដើមទុនដែលជាប់ប្រើការ (វៀរលែងតែដើមទុននេះបានមកពីខ្ចីគេ)

២_ ចំនួនប្រាក់ដែលទុកសំរាប់ធ្វើជាប្រាក់បំរុង ឬសវិធានធន ។ ប៉ុន្តែសវិធានធនទាំងនេះអាចឱ្យរួចពន្ធបានកាលបើសំរាប់ជួសជុលនូវការខូចខាត ឬបន្ទុកដែលមានភាពជាក់ច្បាស់ ហើយបានចុះលេខក្នុងការិយបរិច្ឆេទ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំណត់អំពីបែបបទអនុវត្តការកាត់ចេញនេះ ។

៣_ សោហ៊ុយចំណាយផ្ទាល់ខ្លួនរបស់អាជីវករ

មាត្រា ១៧_ ចំពោះក្រុមហ៊ុនដែលទទួលខុសត្រូវមានខណ្ឌសីមា ប្រាក់តំលៃការដែលបើកឱ្យអ្នកចូលហ៊ុនដែលជាអ្នកចាត់ការហើយ ដែលដាក់ចូលទៅក្នុងប្រាក់សោហ៊ុយ និងជាបន្ទុកនោះ ពុំត្រូវអនុញ្ញាតឱ្យកាត់ចេញទេ បើកាលណាភាគច្រើននៃចំណែកហ៊ុនជារបស់អ្នកចូលហ៊ុន ដែលជាអ្នកចាត់ការ ។

ដើម្បីអនុវត្តនូវបទបញ្ញាត្តិនេះ អ្នកចាត់ការទាំងឡាយដែលពុំមែនជាអ្នកចូលហ៊ុន ត្រូវចាត់ទុកថាជាអ្នកចូលហ៊ុនដែរ បើកាលណាសហព័ទ្ធ ឬកូនរបស់ខ្លួនដែលពុំទាន់បានរួចពីអាណាព្យាបាល មានឋានៈជាអ្នកចូលហ៊ុន ក្នុងករណីនេះក៏ដូចជាករណីដែលអ្នកចាត់ការជាអ្នកចូលហ៊ុនដែរ ត្រូវចាត់ទុកជារបស់អ្នកចាត់ការបណ្តាភាគហ៊ុនដែលជាកម្មសិទ្ធិ ឬសិទ្ធិអាស្រ័យផលរបស់កូនមិនទាន់ចាកផុតពីអាណាព្យាបាល និងសហព័ទ្ធរបស់ខ្លួន ។

មាត្រា១៨_ ក្នុងករណីដែលមានឱនភាពក្នុងការិយបរិច្ឆេទណាមួយ ឱនភាពនោះត្រូវចាត់ទុកជាបន្ទុកសំរាប់ការិយបរិច្ឆេទបន្ទាប់ ហើយត្រូវកាត់ឱនភាពនោះចេញពីប្រាក់ចំណេញសំរេចបានក្នុងការិយបរិច្ឆេទបន្ទាប់នោះ ។ បើប្រាក់ចំណេញនេះមិនគ្រាប់គ្រាន់សំរាប់ទូទាត់ជាស្ថាពរទេ ចំណែកនៃឱនភាពដែលនៅសេសសល់ត្រូវយោងទៅការិយបរិច្ឆេទបន្តបន្ទាប់រហូតដល់ការិយបរិច្ឆេទទី ៣ គិតចាប់ពីការិយបរិច្ឆេទដែលមានឱនភាព ។

មាត្រា១៩_ ដើម្បីគិតពន្ធលើសហគ្រាសដែលនៅក្រោមបង្គាប់ ឬដែលមានការត្រួតត្រានៃសហគ្រាសដែលស្ថិតនៅក្រៅប្រទេសកម្ពុជានោះ ប្រាក់ចំណេញដែលបានផ្ទេរដោយមិនចំពោះឱ្យដល់សហគ្រាសទាំងឡាយដែលនៅក្រៅប្រទេសកម្ពុជា ទោះផ្ទេរដោយផ្លូវបន្ថែម ឬបន្ថយធូរតំលៃទិញ ឬតំលៃលក់ក្តី ទោះដោយមធ្យោបាយដទៃទៀតក្តី ត្រូវបញ្ចូលទៅក្នុងលទ្ធផលដែលគិតឃើញក្នុងបញ្ជីគណនេយ្យ ។

ត្រូវធ្វើដូចគ្នានេះដែរ ចំពោះសហគ្រាសទាំងឡាយដែលស្ថិតក្រោមបង្គាប់នៃសហគ្រាសណាមួយ ឬក្រុមណាមួយដែលមានការត្រួតត្រាសហគ្រាសនៅក្រៅប្រទេសកម្ពុជា ។

បើពុំមានមូលដ្ឋានអ្វីច្បាស់លាស់សំរាប់ធ្វើការកែតំរូវឱ្យបានត្រឹមត្រូវ ដូចមានចែងខាងលើនេះទេ ការកំណត់ផលទាំងឡាយដែលត្រូវជាប់ពន្ធត្រូវបានធ្វើឡើងដោយប្រៀបធៀបទៅនឹងផលរបស់សហគ្រាសដែលមានស្ថានភាពអាជីវកម្មដូចគ្នា ហើយដែលធ្វើអាជីវកម្មធម្មតា ។

មាត្រា២០_ ពន្ធលើប្រាក់ចំណេញត្រូវបង់តាមអត្រាកំណើនតាមថ្នាក់នីមួយលើចំនួនប្រាក់ចំណេញប្រចាំឆ្នាំ ដូចមានកំណត់ក្នុងតារាងខាងក្រោម ៖

| ប្រាក់ចំណេញសំរាប់គិតពន្ធប្រចាំឆ្នាំ | អត្រាពន្ធ |
|---|---|
| ដល់ ១.០០០.០០០៛ | ១០% |
| ពី ១.០០០.០០១៛ ដល់ ១០.០០០.០០០៛ | ១៥% |
| ពី ១០.០០០.០០១ ដល់ ២០.០០០.០០០៛ | ២០% |
| លើសពី ២០.០០០.០០០៛ | ៣០% |

## ផ្នែកទី III

## ភារកិច្ចរបស់អ្នកជាប់ពន្ធ

មាត្រា២១_ អ្នកជាប់ពន្ធលើប្រាក់ចំណេញ ដែលត្រូវបង់ពន្ធតាមរបបពិតនោះ ត្រូវធ្វើជូនជារៀងរាល់ឆ្នាំទៅអង្គការពន្ធនូវលិខិតប្រកាសអំពីប្រាក់ចំណេញដែលខ្លួនបានសំរេចក្នុងឆ្នាំមុន ឬក្នុងការិយបរិច្ឆេទដែលគិតបញ្ជីក្រោយបង្អស់ ។ លិខិតប្រកាសនោះត្រូវចុះបញ្ជីជាដាច់ខាតក្នុងរយៈពេល៣ខែ ក្រោយពីដំណាច់ឆ្នាំឬពីពេលវេលាបិទការិយបរិច្ឆេទដែលគិតបញ្ជីក្រោយបង្អស់នោះ ហើយត្រូវភ្ជាប់មកជាមួយនូវឯកសារដូចតទៅ ៖

១_ តុល្យការ

២_ គណនីលទ្ធផល

៣_ តារាងស្ដីពីព័ត៌មានបន្ថែម

ចំពោះសហគ្រាសដែលមានឱនភាពក៏ត្រូវធ្វើលិខិតប្រកាសអំពីចំនួនខាតនោះតាមបែបបទនិងរយៈវេលាដូចគ្នា។

មាត្រា២២_ អ្នកជាប់ពន្ធលើប្រាក់ចំណេញត្រូវបង់រំដោះនូវពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំលើមូលដ្ឋាន ០.៥% (សូន្យក្បៀសប្រាំភាគរយ) សរុបផលរបរដែលសហគ្រាសរបស់ខ្លួនទាំងអស់សំរេចបាន ក្នុងពេលជាមួយគ្នានិងក្នុងលក្ខខ័ណ្ឌដូចគ្នានឹងការបង់អាករលើផលរបរជូនទៅអង្គការពន្ធ ។

ក្នុងករណីដែលសហគ្រាសត្រូវបានលក់ ប្រាក់រំដោះដែលបានបង់រួចមកហើយ ត្រូវកាត់បញ្ចូលទៅក្នុងគណនីនៃអ្នកទិញដែលជាអ្នកទទួលខុសត្រូវទាំងស្រុងនូវប្រាក់ពន្ធចាប់ពីថ្ងៃលក់សហគ្រាសនោះ ។

នៅពេលគិតពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំអង្គការពន្ធត្រូវផាត់ចេញពីចំនួនប្រាក់ពន្ធត្រូវបង់នូវសរុបប្រាក់រំដោះដែលបានបង់រួចនោះ ហើយផ្ដល់ដំណឹងជាលាយលក្ខណ៍អក្សរជូនអ្នកជាប់ពន្ធឱ្យបង់បង្គ្រប់ ដើម្បីធ្វើការទូទាត់ជាស្ថាពរ ។

បើសរុបទឹកប្រាក់រំដោះមានចំនួនច្រើនជាងប្រាក់ពន្ធត្រូវបង់ ចំនួនទឹកប្រាក់លើសនេះចាត់ទុកជាប្រាក់រំដោះសំរាប់ឆ្នាំក្រោយ ឬបង្វិលសងវិញក្នុងករណីដែលសហគ្រាសត្រូវបានបញ្ឈប់ ។

មាត្រា២៣_ អ្នកជាប់ពន្ធតាមរបបម៉ៅការត្រូវធ្វើលិខិតប្រកាសជូនអង្គការពន្ធក្នុងមូលដ្ឋានដែលខ្លួនមានសកម្មភាពអាជីវកម្មជារៀងរាល់ដំណាច់ឆ្នាំដែលកំពុងប្រកបកិច្ចការយ៉ាងយឺតបំផុតនៅថ្ងៃទី៣១ ខែតុលា តាមគំរូដែលអង្គការពន្ធបានផ្ដល់ជូន ។ ចំនួនប្រាក់ចំណេញម៉ៅការត្រូវកំណត់ដោយអង្គការពន្ធបន្ទាប់ពីត្រួតពិនិត្យនិងពិភាក្សាជាមួយអាជីវករឬអ្នកតំណាង ។ ប្រាក់ចំណេញម៉ៅការនេះត្រូវគិតតាមអត្រាចំណេញដោយយោលតាមប្រភេទនិងតាមមុខរបរអាជីវកម្មដែលនឹងមានកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

កំរិតពន្ធនេះត្រូវកំណត់ជាសារវន្តសំរាប់រយៈពេលមួយមានកំណត់៣ខែ ៦ខែ មួយឆ្នាំ ។ អ្នកជាប់ពន្ធលើប្រាក់ចំណេញតាមរបបម៉ៅការត្រូវបង់ពន្ធនេះប្រចាំខែជារៀងរាល់ខែតាមពេលកំណត់ដោយអង្គការពន្ធ។

## ផ្នែកទីIV

## សិទ្ធិទាក់ទងពត៌មាន

មាត្រា២៤_ អង្គការពន្ធមានសមត្ថកិច្ចត្រូវត្រួតពិនិត្យមើលរាល់លិខិតប្រកាស មានសិទ្ធិអាចសួររកនូវសេចក្ដីបំភ្លឺនិងសេចក្ដីបញ្ជាក់អំពីអ្នកជាប់ពន្ធ មានសិទ្ធិកែតំរូវលិខិតប្រកាសប៉ុន្តែត្រូវឱ្យដំណឹងដល់សាមីខ្លួនអ្នកជាប់ពន្ធជាមុនអំពីមូលដ្ឋានដែលខ្លួនបំរុងនិងចាត់ទុកជាគោលសំរាប់គិតយកពន្ធ ហើយត្រូវប្រាប់សាមីខ្លួនអ្នកជាប់ពន្ធទាំងនេះឱ្យទទួលយល់ព្រម ឬឱ្យធ្វើជូនមកនូវសេចក្ដីយល់ព្រមទទួល ឬនូវយោបល់របស់គេក្នុងរយៈពេល១ខែ ។ បើពុំមានចំលើយក្នុងរយៈវេលានេះទេ អង្គការពន្ធត្រូវកំរិតនូវកាលសំរាប់គិតយកពន្ធ។ សាមីខ្លួនមានសិទ្ធិតវ៉ាបាននៅវេលាក្រោយដែលធ្វើបញ្ជីរួចហើយ ប៉ុន្តែត្រូវជូនភស្តុតាងពិតប្រាកដដែលខ្លួនលើកមកអះអាងនោះ។

បើសាមីខ្លួនបានជូនយោបល់មកក្នុងរយៈពេលមួយខែដូចពោលខាងលើនេះ ហើយអង្គការពន្ធនៅតែប្រកាន់សេចក្តីដែលខ្លួនបានកែតំរូវនោះ អង្គការពន្ធអាចដាក់ពន្ធបាន ប៉ុន្តែសាមីអ្នកជាប់ពន្ធមានសិទ្ធិតវ៉ាក្រោយពេលដែលធ្វើបញ្ជីពន្ធរួច ។ អង្គការពន្ធត្រូវបង្ហាញនូវភស្តុតាងដែលជាមូលដ្ឋាននៃការកែតំរូវនោះដល់អ្នកជាប់ពន្ធ ។

# ពន្ធលើឈ្នួលផ្ទះ និងដី

## ផ្នែកទី I

## បទបញ្ញត្តិទូទៅ

មាត្រា២៥_ ត្រូវបានបង្កើតពន្ធលើប្រាក់ឈ្នួលផ្ទះ និងដី ដើម្បីជាប្រយោជន៍ដល់ថវិការដ្ឋ ។

មាត្រា២៦_ ពន្ធលើប្រាក់ឈ្នួលផ្ទះ និងដីត្រូវកំណត់យកលើប្រាក់ឈ្នួលដែលបានមកពីការជួល ៖

_អាគារដែលសង់លើដីដូចជា ៖ ផ្ទះ រោងចក្រ សណ្ឋាគារ ការិយាល័យ ។ល។

_យន្តូបករណ៍ដែលជាប់ជាមួយគ្រឹះស្ថានឧស្សាហកម្ម

-ប៉ាបនភ័ណ្ឌពាណិជ្ជកម្ម ឧស្សាហកម្ម ដែលនៅនឹងមួយកន្លែង អាគារធំៗដែលទុកដាក់ធាតុរាវឬផលិតផលផ្សេងៗ ដូចជាប្រេងឥន្ធនៈ កៅស៊ូចាក់ថ្នល់ គ្រាប់ធញ្ញជាតិ ។

-ផ្ទះអណ្តែតទឹក កប៉ាល់សំរាប់ធ្វើលំនៅដ្ឋាន ឬដើម្បីប្រកបអាជីវកម្មផ្សេងៗ

-ដីធ្លីដែលគ្មានសំណង់ ដោយរាប់បញ្ចូលទាំងកន្លែងយកថ្ម យកដី ឲ្យងថ្ម បឹងបួរឬស្រែអំបិល ។

មាត្រា២៧_ ពន្ធលើប្រាក់ឈ្នួលផ្ទះនិងដីនេះមិនត្រូវអនុវត្តលើ

-ប្រាក់ឈ្នួលផ្ទះនិងដីដែលបានគិតបញ្ចូលក្នុងប្រាក់ចំណេញនៃសហគ្រាសឧស្សាហកម្ម សិប្បកម្ម កសិកម្ម ពាណិជ្ជកម្ម ឬមុខរបររពាណិជ្ជកម្មណាមួយដែលស្ថិតក្នុងក្របខ័ណ្ឌត្រូវយកពន្ធលើប្រាក់ចំណេញតាមរបបពិតប្រាកដ ។

-ប្រាក់ដែលអ្នកជួលបានតំកល់ទុកធ្វើប្រាក់ធានា ហើយនៅពេលផុតកិច្ចសន្យា កម្មសិទ្ធិករត្រូវប្រគល់គ្រប់ចំនួនឱ្យអ្នកជួលវិញ ។

មាត្រា២៨_ ពន្ធនេះត្រូវប្រមូលពីកម្មសិទ្ធិករ ឬសិទ្ធិវន្តរបស់កម្មសិទ្ធិករ ។

មាត្រា២៩_ អត្រាឈ្នួលផ្ទះ និងដីត្រូវបានកំណត់ស្មើនឹង ១០% នៃប្រាក់ឈ្នួលដុល ។ ប្រាក់ឈ្នួលដុលគឺជាប្រាក់ឈ្នួលដែលបានចុះកិច្ចសន្យា ឬបានព្រមព្រៀងជាមួយអ្នកជួល ។

មាត្រា៣០_ ត្រូវបានលើកលែងមិនប្រមូលចំពោះប្រាក់ឈ្នួលផ្ទះ និងដីដែលមានកំរិតទាប ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានសមត្ថកិច្ចកំណត់អំពីការលើកលែងនេះ ។

មាត្រា៣១_ ពន្ធលើប្រាក់ឈ្នួលផ្ទះ និងដីត្រូវបង់ប្រចាំខែជារៀងរាល់ខែគិតចាប់ពីថ្ងៃដែលបានចុះកិច្ចសន្យា ឬបានព្រមព្រៀងគ្នា ។

# ផ្នែកទី II

# ភារកិច្ចរបស់កម្មសិទ្ធិករ និងអ្នកជួល

មាត្រា៣២_កម្មសិទ្ធិករមានភារកិច្ចដូចតទៅ ៖

ក_ត្រូវប្រកាសក្នុងរយៈពេល ១៥ថ្ងៃគិតពីចុះកិច្ចសន្យាជួល ឬចាប់ពីថ្ងៃមានការប្រែប្រួលអំពីកិច្ចសន្យាជូនទៅអង្គការពន្ធនៅក្នុងមូលដ្ឋាន ដែលកម្មវត្ថុនៃកិច្ចសន្យានោះតាំងនៅតាមគំរូដែលអង្គការពន្ធផ្តល់ឱ្យ និងត្រូវផ្ញើភ្ជាប់មកជាមួយនូវច្បាប់ថតចំលងនៃកិច្ចសន្យាជួលចំនួនមួយច្បាប់ ។

ខ_ពេលឈប់ឈ្នួលក្នុងរវាង១៥ថ្ងៃត្រូវប្រកាសជាលាយលក្ខណ៍អក្សរជូនទៅអង្គការពន្ធដែលបានទទួលប្រកាសពីមុនពាក្យប្រកាសទាំងឡាយត្រូវមានចុះកាលបរិច្ឆេទ និងហត្ថលេខាដោយត្រឹមត្រូវរបស់កម្មសិទ្ធិករឬអ្នកទទួលអាណត្តិ ដោយបានអនុញ្ញាត្តិ ។

គ_ផ្តល់បង្កាន់ដៃទទួលប្រាក់ឈ្នួលជូនអ្នកជួលក្នុងពេលទទួលប្រាក់ឈ្នួលម្តង ៗ

ឃ_ក្នុងរយៈពេលកំណត់ត្រូវបង់ឱ្យគ្រប់ចំនួននូវប្រាក់ពន្ធ ឬប្រាក់ពិន័យដែលអង្គការពន្ធបានកំណត់ ។

មាត្រា៣៣_ ក_ក្នុងករណីដែលកម្មសិទ្ធករមិនព្រមបង់ពន្ធលើឈ្នួលផ្ទះ ឬដីនោះអ្នកជួលមានភារៈកិច្ចទទួលខុសត្រូវដកប្រាក់ថ្លៃឈ្នួល ដើម្បីបង់ពន្ធឱ្យគ្រប់ចំនួន ។

ខ_អ្នកជួលផ្ទះឬដីត្រូវបង្ហាញបង្កាន់ដៃទទួលប្រាក់ដែលកម្មសិទ្ធិករផ្តល់ជូន និងត្រូវផ្តល់ពត៌មានផ្សេងៗទៀតដែលទាក់ទងដល់ការជួលចំពោះភ្នាក់ងារពន្ធដែលមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យ ។

# អាករលើផលរបរ

# ផ្នែកទី I

## បទបញ្ញត្តិទូទៅ

មាត្រា៣៤_ ត្រូវបានបង្កើតអាករ ដើម្បីជាប្រយោជន៍ដល់ថវិការដ្ឋ

មាត្រា៣៥_ បុគ្គលិកណាដែលប្រកបរបរ ទិញសំរាប់លក់ទៅវិញមួយដងមួយគ្រា ឬជានិច្ចជាកាល ឬប្រកបវិជ្ជាជីវៈខាងពាណិជ្ជកម្ម

*មាត្រា៣០* ._ ត្រូវបានលើកលែងមិនប្រមូលពន្ធចំពោះប្រាក់ឈ្នួលផ្ទះ និង ដី ដែលមានកំរិតទាប ។
រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានសមត្ថកិច្ចកំណត់អំពីការលើកលែងនេះ ។

*មាត្រា៣១* ._ ពន្ធលើប្រាក់ឈ្នួលផ្ទះ និងដីត្រូវបង់ប្រចាំខែជារៀងរាល់ខែ គិតចាប់ពីថ្ងៃដែលបានចុះកិច្ចសន្យា ឬបានព្រមព្រៀងគ្នា ។

## ផ្នែកទី II

## ភារកិច្ចរបស់កម្មសិទ្ធិករ និង អ្នកជួល

*មាត្រា៣២* ._ កម្មសិទ្ធិករមានភារកិច្ចដូចតទៅ ៖

ក_ ត្រូវប្រកាសក្នុងរយៈពេល១៥ថ្ងៃ គិតពីថ្ងៃចុះកិច្ចសន្យាជួល ឬ ចាប់ពីថ្ងៃមានការប្រែប្រួលអំពីកិច្ចសន្យា ជូនទៅអង្គការពន្ធនៅក្នុងមូលដ្ឋាន ដែលកម្មវត្ថុនៃកិច្ចសន្យានោះតាំងនៅតាមគំរូដែលអង្គការពន្ធផ្តល់អោយ និង ត្រូវជូនភ្ជាប់មកជាមួយនូវច្បាប់ចតចំលងនៃកិច្ចសន្យាជួលចំនួនមួយច្បាប់ ។

ខ_ ពេលឈប់ជួលក្នុងរវាង១៥ថ្ងៃ ត្រូវប្រកាសជាលាយលក្ខណ៍អក្សរ ជូនទៅអង្គការពន្ធដែលបានទទួលប្រកាសពីមុន ពាក្យប្រកាសទាំងឡាយត្រូវមានចុះកាលបរិច្ឆេទ និង ហត្ថលេខាដោយត្រឹមត្រូវរបស់កម្មសិទ្ធិករ ឬ អ្នកទទួលអាណត្តិដោយបានអនុញ្ញាត្តិ ។

គ_ ផ្តល់បង្កាន់ដៃទទួលប្រាក់ឈ្នួលជូនអ្នកជួលក្នុងពេលទទួលប្រាក់ឈ្នួលម្តង ៗ ។

ឃ_ ក្នុងរយៈពេលកំណត់ត្រូវបង់អោយគ្រប់ចំនួននូវប្រាក់ពន្ធ ឬ ប្រាក់ពិន័យ ដែលអង្គការពន្ធបានកំណត់ ។

*មាត្រា៣៣* ._ ក_ ក្នុងករណីដែលកម្មសិទ្ធិករ មិនព្រមបង់ពន្ធលើឈ្នួលផ្ទះ ឬ ដីនោះ អ្នកជួលមានភារកិច្ចទទួលខុសត្រូវ ដកប្រាក់ថ្លៃឈ្នួលយកមកបង់ពន្ធអោយគ្រប់ចំនួន ។
ខ_ អ្នកជួលផ្ទះ ឬ ដី ត្រូវបង្ហាញបង្កាន់ដៃទទួលប្រាក់ដែលកម្មសិទ្ធិករផ្តល់ជូន និង ត្រូវផ្តល់ពត៌មានផ្សេងៗទៀតដែលទាក់ទងដល់ការជួលចំពោះភ្នាក់ងារពន្ធដែលមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យ ។

## *អាករលើផលរបរ*

## ផ្នែកទី I

## បទបញ្ញត្តិទូទៅ

*មាត្រា៣៤* ._ ត្រូវបានបង្កើតអាករលើផលរបរ ដើម្បីជាប្រយោជន៍ដល់ថវិការដ្ឋ ។

*មាត្រា៣៥* ._ បុគ្គលណាដែលប្រកបរបរទិញសំរាប់លក់ទៅវិញមួយដងមួយគ្រា ឬ ជានិច្ចជាកាល ឬ ប្រកបវិជ្ជាជីវៈខាងពាណិជ្ជកម្ម .

ឧស្សាហកម្ម សិប្បកម្ម សេវាកម្ម ដោយរាប់បញ្ចូលទាំងអាជីវកម្មព្រៃឈើ អណ្តូងរ៉ែ និង នេសាទ នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា របរនៃបុគ្គលនោះត្រូវជាប់អាករលើផលរបរ ។

កិច្ចប្រតិបត្តិការទាំងឡាយដែលសមូហភាព ឬ អង្គការណាមួយធ្វើខ្លួនឯង ឬ ប្រគល់សម្បទានអោយគេធ្វើជួសក្នុងមុខរបរដែលមានចែងខាងលើ ក៏ត្រូវជាប់អាករលើផលរបរនេះផងដែរ ។

មាត្រា៣៦ .. អាករលើផលរបរត្រូវបង់មូល

១. នៅទីតាំងនៃគ្រឹះស្ថាននិមួយៗបើអ្នកជាប់អាករមានគ្រឹះស្ថានមួយ ឬ ក៏ច្រើន ។

២. នៅទីលំនៅ ឬ ទីសំចតនៃអ្នកតំណាងដោយត្រឹមត្រូវ ដូចមានចែងក្នុងមាត្រា ៩២ បើអ្នកជាប់អាករគ្មានគ្រឹះស្ថានក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា៣៧ .. របរផ្សេងក្រៅពីការលក់ដូរត្រូវកំណត់អាករនៅកន្លែងដែលអោយខ្ចី ឬ អោយជួលកិច្ចការដែលបានធ្វើ ឬ សេវាដែលបានផ្តល់ ទោះបីវត្ថុដែលអោយខ្ចី ឬ អោយជួលកិច្ចការដែលបានធ្វើ ឬ សេវាដែលបានផ្តល់នោះនៅទីណាក៏ដោយ ។

មាត្រា៣៨ .. ការកំណត់អាករលើផលរបរនេះ ត្រូវអនុវត្តតាមរបបពិតប្រាកដ និង តាមវិធីទៅការ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ កំណត់តាមប្រកាសអំពីរបៀបបទកំណត់អាករនេះ ដោយយោលតាមមុខរបរកិតផលរបរ និង ទំហំទ្រង់ទ្រាយអាជីវកម្ម ។

មាត្រា៣៩ .. ត្រូវបានលើកលែងអាករលើផលរបរចំពោះ ៖

១. ការលក់ដូរផលិតផលកសិកម្មរបស់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលផលិតបានដោយខ្លួនឯង ទោះបីផលិតផលនោះមិនទាន់កែច្នៃ ឬ ក៏កែច្នៃហើយ តាមទំលាប់នៃការងារកសិកម្ម ។

២. ការលក់ដូរទំនិញនាំចូល ដែលអ្នកនាំចូលលក់ទំនិញនោះផ្ទាល់ខ្លួននៅក្នុងប្រទេស ឬ ចេញទៅក្រៅប្រទេស ក្នុងករណីទំនិញនាំចូលទាំងនោះបានបង់អាករប្រើប្រាស់ដូចបានចែងក្នុងផ្នែកទី III ខាងក្រោម ។

<u>៣. អាជីវកម្មខ្នាតតូច និង អចលនវត្ថុបាចដែលនឹងកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ</u> ។

មាត្រា៤០ .. ការលើកលែងអាករដែលមានចែងក្នុងចំណុច១នៃមាត្រា ៣៩ មិនត្រូវអនុវត្តចំពោះការលក់ដូរផលិតផលកសិកម្មផ្សេងៗដែលបានយកមកកែច្នៃរក្សាទុកសំរាប់លក់ និង ការរៀបចំតាមបែបផ្សេងទៀត អាស្រ័យដោយប្រើប្រាស់ឧបករណ៍ឧស្សាហកម្ម ឬតាមវិធីពាណិជ្ជកម្មណាមួយនោះដែលពុំអាចចាត់ទុកថាជាផលិតផលបន្ទាប់បន្សំ ឬជាការបន្តធម្មតានៃការងារកសិកម្មឡើយ ។

## ផ្នែកទី II

## អំពីមូលដ្ឋានគិតអាករ និង អត្រាអាករ

មាត្រា៤១ .. អាករនេះ ត្រូវកំណត់លើចំនួនប្រាក់ដែលលក់បាន ដោយគិតទាំងសោហ៊ុយ និង ពន្ធដារផង ឬ មួយគិតតាមតំលៃវត្ថុដែលបានទទួលមកជាថ្នូរ ទាក់ទងទៅនឹង ៖

១. បុគ្គលទាំងឡាយដែលលក់ ឬដោះដូរទំនិញសំភារៈ វត្ថុ ហើយបើនិយាយជាទូទៅគឺ សង្ហារឹមវត្ថុ ឬអសង្ហារឹមវត្ថុទាំងឡ

២. បុគ្គលទាំងឡាយដែលប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា សំរាប់ហាងជំនួញតែគ្មានគ្រឹះស្ថានតាំងនៅក្នុងប្រទេសកម្ពុជា ។

៣_ អ្នកទទួលកំរៃជើងសារ អ្នកតំណាង អ្នកទទួលអាណត្តិ ឬ អ្នកកណ្តាលទាំងឡាយដែលមានលក្ខណៈមិនមែនត្រឹមតែកំរៃជើងសារប៉ុណ្ណោះ គឺកំរៃជើងសារដែលមានកំណត់ទុកជាមុនតាមតំលៃ ឬបរិមាណរាំគទំនិញ ហើយបញ្ចូលគុណប្រយោជន៍ផ្សេងក្នុងកំរៃជើងសារនោះថែមទៀត ឬ មិនរាយការណ៍ជាលាយលក្ខណ៍អក្សរប្រាប់អ្នកដែលប្រគល់ការអោយខ្លួនអំពីតំលៃដែលបានព្រមព្រៀងនឹងគូភាគីម្ខាងទៀត ។

**មាត្រា៤២** ._ សំរាប់បុគ្គលដែលប្រព្រឹត្តកិច្ចការជាអ្នកទទួលកំរៃជើងសារ អ្នកតំណាង អ្នកទទួលអាណត្តិ អ្នកកណ្តាល ជាងម៉ៅខុងការ អ្នកជួលវត្ថុ ឬ សេវាកម្ម ជនាវាសិក អប្បហារី អ្នកដូរប្រាក់ អាករលើផលរបរត្រូវគិតលើប្រាក់កំរៃប្រាក់លោះថ្លៃ ប្រាក់ថ្លៃឈ្នួល ចុងការ និង គុណប្រយោជន៍ផ្សេងៗទៀត ។

**មាត្រា៤៣** ._ សរាចសរពគ្រាសម៉ៅការ អាករលើផលរបរត្រូវគិតយកលើតំលៃការដែលបញ្ជាក់ ឬ ទឹកប្រាក់ក្នុងសារណា ឬ ទឹកប្រាក់ក្នុងវិក្កយប័ត្រ រួមបញ្ចូលទាំងសោហ៊ុយ និង អាករគ្រប់មុខផង ។

**មាត្រា៤៤** ._ អត្រាអាករលើផលរបរត្រូវកំណត់ ១% " មួយភាគរយ " ចំពោះកិច្ចការខាងឧស្សាហកម្ម សិប្បកម្ម និង អណ្តូងរ៉ែ ។ ក្រៅពីនេះ ត្រូវកំណត់ ២% " ពីរភាគរយ " វៀរលែងតែករណីមានចែងក្នុង មាត្រា ៤៥ និង ៤៦ នៃច្បាប់ហិរញ្ញវត្ថុនេះ ។

**មាត្រា៤៥** ._ អាករលើផលរបរត្រូវឡើងដល់ ១០% ចំពោះ ៖

១_ ផលរបរផ្សេងៗទៀតរបស់សណ្ឋាគារក្រៅពីឈ្នួលបន្ទប់

២_ ផលរបរនៃអាជីវកម្ម មាស្សា និង រង្គសាល

៣_ ផលរបររបស់ភោជនីយដ្ឋាន ភេសជ្ជៈដ្ឋាន និង សប្បាយដ្ឋាន ដែលមានប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទុកជាគ្រឹះស្ថានលើកតាមសេចក្តីស្នើនៃគណៈកម្មការដែលតាំងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ផ្នែកទី III

## កិច្ចការនាំទំនិញចូល

**មាត្រា៤៦** ._ កិច្ចការនាំទំនិញចូល ត្រូវបង់អាករលើផលរបរហៅថា អាករប្រើប្រាស់តាមអត្រា ៤% " បួនភាគរយ " លើតំលៃក្រៅគយ ។

**មាត្រា៤៧** ._ អាករប្រើប្រាស់ត្រូវប្រមូលក្នុងពេលដំណាលគ្នានឹងការប្រមូលពន្ធលើទំនិញនាំចូល និង ត្រូវប្រមូលដោយអគ្គការគយ ។

**មាត្រា៤៨** ._ ការពិន័យជាប្រាក់ និង ពិន័យថ្នែករដ្ឋបាល ទាក់ទងនឹងពន្ធលើការប្រើប្រាស់ គឺ ស្ថិតនៅក្រោមអំណាចនៃច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ នាំចូលដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩

## ផ្នែកទី IV

## ភារកិច្ចរបស់អ្នកជាប់អាករ

**មាត្រា៤៩ :** អ្នកជាប់អាករលើផលរបរមានភារកិច្ចដូចតទៅ ៖

ក_ ត្រូវប្រកាសក្នុងរយៈពេល១៥ថ្ងៃ គិតពីថ្ងៃចាប់ផ្តើមប្រកបអាជីវកម្ម ឬ ចាប់ពីថ្ងៃមានការប្រែប្រួលអំពីស្ថានភាពអាជី ជូនទៅអង្គការពន្ធនៅក្នុងមូលដ្ឋាន ដែលគ្រឹះស្ថានរបស់ខ្លួនតាំងនៅ តាមគំរូដែលអង្គការពន្ធផ្តល់អោយ ។

ខ_ ពេលឈប់ប្រកបអាជីវកម្មរបស់ខ្លួន ឬ ផ្ទេរអាជីវកម្មរបស់ខ្លួនអោយអ្នកដទៃ ព្រមទាំងអ្នកទទួលផ្ទេរនោះជងត្រូវប្រ ក្នុងរវាង ១៥ថ្ងៃ ជូនទៅអង្គការពន្ធដែលបានទទួលពាក្យប្រកាសពីមុន ។

គ_ ត្រូវកាន់ និង ថែរក្សាបញ្ជីគណនេយ្យ សក្ខីប័ត្រ អោយបានត្រឹមត្រូវតាមរបបគណនេយ្យដែលរដ្ឋបានកំណត់ និង តាម ការណែនាំរបស់អង្គការពន្ធ ហើយត្រូវបង្ហាញបញ្ជីគណនេយ្យ និងសក្ខីប័ត្រទាំងនោះដល់អង្គការពន្ធក្នុងពេលចាំបាច់ ។

ឃ_ ត្រូវដាក់អោយស្ថិតក្រោមការត្រួតពិនិត្យរបស់អង្គការពន្ធចំពោះទំនិញដែលស្ថិតក្នុងអាគារលក់ដូរ ឬ ឃ្លាំង ។

**មាត្រា៥០ ._** ចំពោះអ្នកជាប់អាករតាមរបបពិតប្រាកដ នៅមុនថ្ងៃទី១០រាល់ខែ ត្រូវធ្វើជូនទៅអង្គការពន្ធនូវលិខិតប្រកាសផលរបរនៃ អាជីវកម្មរបស់ខ្លួនក្នុងខែមុនហើយត្រូវបង់អាករទៅតាមចំនួនផលរបរដែលបានប្រកាសនោះ ។ លិខិតប្រកាសនេះត្រូវមាន ចុះកាលបរិច្ឆេទ និង ហត្ថលេខានៃអ្នកជាប់អាករ ឬ អ្នកទទួលអាណាព្យាបាលដោយបានអនុញ្ញាត ។
បើក្នុងខែណាមួយ ពុំបានប្រកបកិច្ចការជាប់អាករអ្វីមួយទេ ក៏ត្រូវធ្វើលិខិតប្រកាសថា " គ្មាន " ជូនទៅដែរ ។
បើអ្នកជាប់អាករមានគ្រឹះស្ថានច្រើនកន្លែង ត្រូវធ្វើលិខិតប្រកាសផលរបរនោះមួយច្បាប់សំរាប់គ្រឹះស្ថាននិមួយៗ ។

**មាត្រា៥១ ._** ចំពោះអ្នកជាប់អាករតាមរបបម៉ៅការត្រូវធ្វើលិខិតប្រកាសជូនអង្គការពន្ធក្នុងមូលដ្ឋានដែលខ្លួនមានសកម្មភាពអាជីវកម្មជា រៀងរាល់ឆ្នាំមុនពេលផុតឆ្នាំដែលកំពុងប្រកបកិច្ចការយ៉ាងយឺតបំផុតនៅថ្ងៃ ៣១ ខែតុលា តាមគំរូដែលអង្គការពន្ធ បានផ្តល់ជូន ។
ប្រាក់អាករដែលត្រូវបង់ ត្រូវផ្អែកជាមូលដ្ឋានលើផលរបរប្រចាំខែកំណត់ដោយអង្គការពន្ធបន្ទាប់ពីបានត្រួតពិនិត្យ និង ពិភាក្សាជាមួយអាជីវករ ឬ អ្នកតំណាង ។
កំរិតអាករនេះត្រូវកំណត់ជាស្ថេរវត្ត សំរាប់រយៈពេលមួយមានកំណត់ ៣ខែ. ៦ខែ. ១ឆ្នាំ ។
អ្នកជាប់អាករតាមរបបម៉ៅការ ត្រូវបង់អាករនេះប្រចាំខែជារៀងរាល់ខែតាមពេលកំណត់ដោយអង្គការពន្ធ ។

**មាត្រា៥២ ._** ផ្ទះជំនួញណាដែលតាំងនៅក្រៅប្រទេសកម្ពុជា បើប្រកបអាជីវកម្មក្នុងប្រទេសកម្ពុជាត្រូវជូនឈ្មោះអ្នកតំណាង ម្នាក់ដែលមានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជាទៅអង្គការពន្ធអោយទទួលស្គាល់ផង ។ អ្នកតំណាងនោះ ត្រូវទទួលខ្លួនប្រតិបត្តិតាមបែបបទដែលអ្នកជាប់អាករលើផលរបរទាំងឡាយត្រូវធ្វើ ហើយត្រូវសន្យាបង់អាករលើ ផលរបរជួសផ្ទះជំនួញនោះ ។

## ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ

មាត្រា៩៣_

មាត្រា២នៃច្បាប់ស្តីពីការបង្កើតពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទដែលប្រកាសឱ្យប្រើ ដោយក្រឹត្យលេខ ២៤ ក្រ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ១៩៩១ ត្រូវបានកែប្រែដូចខាងក្រោម ៖

មាត្រា២ ថ្មី :

ពន្ធខាងលើត្រូវអនុវត្តទៅលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ តាមការកំណត់ដូចខាងក្រោម៖

| ប្រភេទមធ្យោបាយដឹកជញ្ជូន និងយានជំនិះ | កំរិតប្រាក់ពន្ធសំរាប់មួយឆ្នាំក្នុងមួយគ្រឿង | |
|---|---|---|
| _រថយន្តដឹកទំនិញ ធុនធ្ងន់ | ១៥០.០០០ | |
| _រថយន្តដឹកទំនិញ ធុនស្រាល | ៧៥.០០០ | |
| _រថយន្តដឹកអ្នកដំណើរឆ្លងកាត់ខេត្ត ក្រុង ធុនធំមានលើសពី៣០កៅអី | ១២០.០០០ | |
| _រថយន្តដឹកអ្នកដំណើរឆ្លងកាត់ខេត្ត ក្រុង ធុនមធ្យមមាន៣០កៅអីចុះ | ៩០.០០០ | |
| _រថយន្តដឹកអ្នកដំណើរក្នុង ក្រុង ធុនធំ មានលើសពី ៣០កៅអី | ៩០.០០០ | |
| _រថយន្តដឹកអ្នកដំណើរក្នុង ក្រុង ធុនមធ្យមមាន៣០កៅអីចុះ | ៦០.០០០ | |
| _រថយន្តទេសចរណ៍គ្រប់ប្រភេទ | គិតពីឆ្នាំផលិត | |
| | ដល់ ៥ ឆ្នាំ | លើសពី ៥ ឆ្នាំ |
| _កម្លាំងដល់ ៩ សេស | ៥០.០០០ | ៣៧.៥០០ |
| _កម្លាំងពី ៩ សេស ដល់ ១២ សេស | ៧៥.០០០ | ៥០.០០០ |
| _កម្លាំងពី ១២ សេសឡើងទៅ | ១២៥.០០០ | ៨៧.៥០០ |
| _ត្រាក់ទ័រកម្លាំង ៨២ សេស | ១៥.០០០ | |
| _ត្រាក់ទ័រកម្លាំង ៦៥ សេស | ៩.០០០ | |
| _ត្រាក់ទ័រកម្លាំង ៣៥ សេស | ៣.០០០ | |
| _ទោចក្រយានយន្តទំហំពិសស្តុង ៧០ ស.ម$^{៣}$ ចុះ | ៣.០០០ | |
| _ទោចក្រយានយន្តទំហំពិសស្តុង ៧០ ស.ម$^{៣}$ ទៅ ១២០ ស.ម$^{៣}$ | ៤.៥០០ | |
| _ទោចក្រយានយន្តទំហំពិសស្តុងចាប់ពី ១២៥ ស.ម$^{៣}$ ឡើងទៅ | ៧.៥០០ | |
| _ត្រីចក្រយានយន្តដឹកទំនិញ ឬអ្នកដំណើរ | ១៥.០០០ | |

| | |
|---|---|
| **ចលយាន ឬចលយានយន្ត ផ្លូវទន្លេ** | |
| -កប៉ាល់ដឹកអ្នកដំណើរបណ្ដោយលើសពី ៣០ម | ១៥០.០០០ |
| -កប៉ាល់ដឹកអ្នកដំណើរបណ្ដោយលើសពី ២០ម ដល់ ៣០ម | ១០០.០០០ |
| -កប៉ាល់ដឹកអ្នកដំណើរបណ្ដោយ ២០ម ចុះ | ៥០.០០០ |
| -កប៉ាល់សណ្ដោងមានកំលាំងពី ៣០សេស ដល់ ៥០សេស | ៨.០០០ |
| -កប៉ាល់សណ្ដោងមានកំលាំងពី ៥០សេស ដល់ ១០០សេស | ១៥.០០០ |
| -កប៉ាល់សណ្ដោងមានកំលាំងពី ១០០សេស ដល់ ១៥០សេស | ២៥.០០០ |
| -កប៉ាល់សណ្ដោងមានកំលាំងពី ១៥០សេស ដល់ ២០០សេស | ៣០.០០០ |
| -កប៉ាល់សណ្ដោងមានកំលាំងពី ២០០សេស ដល់ ២៥០សេស | ៨០.០០០ |
| -កប៉ាល់សណ្ដោងមានកំលាំងលើសពី ២៥០សេស | ១៥០.០០០ |
| -ការណូតនេសាទមានកំលាំងពី ១០សេស ទៅ ៥០សេស | ៣.០០០ |
| -ការណូតនេសាទមានកំលាំងពី ៥០សេស ទៅ ១០០សេស | ៨.០០០ |
| -ការណូតនេសាទមានកំលាំងពី ១០០សេស ទៅ ១៥០សេស | ១៥.០០០ |
| -ទូកម៉ាស៊ីនចំហៀង "ជើងបង្កង" | ៥.០០០ |
| -អូបំរ | ២៥០.០០០ |
| **ចលយាន ឬ ចលយានយន្ត ផ្លូវសមុទ្រ** | |
| -កប៉ាល់ដឹកទំនិញផ្ទុកបានត្រឹម១.០០០តោន ត្រូវគិតដូចផ្នែកទឹកសាប | - |
| -កប៉ាល់ដឹកទំនិញផ្ទុកបានលើសពី១.០០០តោន ដល់ ២.០០០តោន | ៧៥០.០០០ |
| -កប៉ាល់ដឹកទំនិញផ្ទុកបានលើសពី ២.០០០តោន | ១.២០០.០០០ |
| -កប៉ាល់នេសាទមានកំលាំងត្រឹម១៥០សេសត្រូវគិតដូចខាងផ្នែកទឹកសាប | - |
| -កប៉ាល់នេសាទមានកំលាំងលើសពី ១៥០សេស ដល់ ២៥០សេស | ១៥០.០០០ |
| -កប៉ាល់នេសាទមានកំលាំងលើសពី ២៥០ សេសដល់ ៥០០សេស | ៣០០.០០០ |
| -កប៉ាល់នេសាទមានកំលាំងលើសពី ៥០០សេស ឡើងទៅ | ៦០០.០០០ |
| -កប៉ាល់សណ្ដោងដែលមានកំលាំងត្រឹម២៥០សេសត្រូវគិតដូចផ្នែកទឹកសាប | - |
| -កប៉ាល់សណ្ដោងដែលមានកំលាំងលើសពី ២៥០សេសដល់៥០០សេស | ១៥០.០០០ |
| -កប៉ាល់សណ្ដោងដែលមានកំលាំងលើសពី ៥០០សេស ឡើង | ៣០០.០០០ |

## ជំពូកទី ៣

## បទបញ្ញត្តិរួមអំពីពន្ធ និង អាករ

**មាត្រា៥៤** ._ ការទទួលធ្វើអោយសំរេច នូវលក្ខណៈបញ្ញត្តិនៃច្បាប់នេះ និង ការពិនិត្យកត់ត្រានូវបទល្មើសទាំងឡាយ គឺជាសមត្ថកិច្ច របស់អង្គការពន្ធ ។

**មាត្រា៥៥** ._ ទោះក្នុងករណីណាក៏ដោយ ក្រុមរាជការទាំងឡាយព្រមទាំងសហគ្រាសដែលរដ្ឋបានអោយសម្បទាន ឬ ដែលរដ្ឋត្រួតត្រា ហើយនិងគ្រឹះស្ថាន ឬ អង្គការសាធារណៈទាំងឡាយ ពុំអាចនឹងលាក់បាំងនូវការសំងាត់ក្នុងវិជ្ជាជីវៈចំពោះភ្នាក់ងារពន្ធ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលបំពេញមុខងារខាងពន្ធអាករនេះហើយដែលមានលិខិតឧទ្ទេសនាម និងលិខិតបញ្ជាបេសកកម្មត្រឹមត្រូវ ។

**មាត្រា៥៦** ._ ក្នុងករណីដែលអ្នកជាប់ពន្ធអាករ ពុំព្រមបង់ប្រាក់ពន្ធអាករ ឬ ប្រាក់ពិន័យអ្នកជាប់ពន្ធអាករអាចតវ៉ាទៅអង្គការពន្ធថ្នាក់លើតាមលំដាប់ថ្នាក់ អោយលុប ឬ បន្ថយប្រាក់ពន្ធអាករ ឬ ប្រាក់ពិន័យដែលតម្រូវអោយបង់នោះ បើមានភស្តុតាងបញ្ជាក់ថា អង្គការពន្ធថ្នាក់នោះកំណត់មិនត្រឹមត្រូវ ។

បើនៅតែមិនយល់ព្រម ត្រូវបញ្ជូនសំណុំរឿងទៅតុលាការដើម្បីជំនុំជំរះ ។

ក្នុងពេលរង់ចាំការដោះស្រាយបណ្តឹងតវ៉ា អ្នកជាប់ពន្ធអាករត្រូវបង់ប្រាក់ពន្ធអាករ និង ប្រាក់ពិន័យអោយគ្រប់តាមចំនួន និងតាមពេលវេលាកំណត់ ។

**មាត្រា៥៧** ._ ការប្រកាសមិនគ្រប់គ្រាន់ ការប្រកាសពុំត្រង់ ជាទូទៅគឺបទល្មើសទាំងពួងលើបទបញ្ញត្តិនៃច្បាប់នេះត្រូវរងការពិន័យជាប្រាក់ពី ១០.០០០៛ ដល់ ៥០.០០០៛ ហើយបើមានការបន្លំពន្ធអាករ ត្រូវរងការពិន័យបន្ថែមស្មើនឹង២ដងនៃប្រាក់ពន្ធអាករដែលបន្លំនោះ ។

ក្នុងរយៈពេល២ឆ្នាំ បើពុំរាងចាលនៅប្រព្រឹត្តល្មើសទៀតនោះ ចំនួនប្រាក់ពិន័យខាងលើត្រូវឡើងពី ២០.០០០៛ ដល់ ១០០.០០០ ៛ ឯប្រាក់ពិន័យពីការបន្លំពន្ធអាករត្រូវស្មើ ៣ ដងនៃប្រាក់ពន្ធអាករដែលបន្លំ ។

**មាត្រា៥៨** ._ ត្រូវរងការកំណត់ពន្ធអាករតាមផ្លូវការ ចំពោះអ្នកជាប់ពន្ធអាករដែល :

១_ ពុំបានប្រកាសជូនអង្គការពន្ធ តាមពេលវេលាដែលកំណត់ក្នុងច្បាប់នេះ

២_ ពុំព្រមបំភ្លឺ ឬ ពុំព្រមជូនភស្តុតាងផ្សេង ៗ តាមការស្នើសុំរបស់អង្គការពន្ធក្នុងរយៈពេល ៣០ ថ្ងៃ

៣_ ពុំព្រមបង្ហាញបញ្ជីគណនេយ្យជូនអង្គការពន្ធ

**មាត្រា៥៩** ._ ចំនួនប្រាក់ពន្ធអាករត្រូវបន្ថែម ២៥ ភាគរយ ចំពោះអ្នកជាប់ពន្ធអាករដែលត្រូវគិតពន្ធអាករតាមផ្លូវការ ។ ចំនួនបន្ថែមនេះត្រូវឡើងដល់ ៥០ ភាគរយក្នុងករណីពុំរាងចាលជាដំបូង ដល់ ១០០ ភាគរយក្នុងករណីពុំរាងចាលលើកទី ២ និងឡើងដល់ ២០០ ភាគរយក្នុងករណីល្មើសបន្តទៀត ។

**មាត្រា៦០** ._ ការយឺតយ៉ាវ មិនបានបង់ប្រាក់ពន្ធអាករតាមពេលកំណត់ត្រូវរងការពិន័យជាប្រាក់ស្មើនឹង ៥ ភាគរយក្នុង ១ ខែ លើចំនួនប្រាក់ពន្ធអាករដែលត្រូវបង់ ចំពោះអំពើល្មើសជាលើកទី ១ ។

ក្នុងរយៈពេលពីរឆ្នាំ បើពុំរាងចាលនៅប្រព្រឹត្តល្មើសទៀតនោះ អត្រាប្រាក់ពិន័យនេះត្រូវឡើងដល់ ១០ ភាគរយ ចំពោះអំពើល្មើសជាលើកទី ២ និងត្រូវឡើងដល់ ១៥ ភាគរយ ចំពោះល្មើសជាលើកទី ៣ ។

ចំពោះអំពើល្មើសជាបន្តទៀត អត្រាប្រាក់ពិន័យត្រូវឡើងដល់ ២០ ភាគរយ ។

ការលើកលែងមិនបានបង់ពន្ធអាករនិងអាចអនុគ្រោះពន្យារពេលបង់ពន្ធអាករ បន្ថយពន្ធអាករ ឬអោយរួចពន្ធអាករ បានតែក្នុងករណីមានមហន្តរាយដល់សកម្មភាពអាជីវកម្ម ឬ ទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធអាករ ឬ អាយុជីវិតរបស់អ្នកជាប់ពន្ធអាករ ។

ការអនុគ្រោះអោយពន្យារពេលបង់ពន្ធអាករ ឬ បន្ថយពន្ធអាករ ឬ អោយរួចពន្ធអាករ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា៦១ .. អង្គការពន្ធមានសិទ្ធិ តាមប្រមូលទារប្រាក់ពិន័យដែលអ្នកប្រព្រឹត្តល្មើសបានយល់ព្រមទទួល និង ប្រាក់ពន្ធអាករភ្លាំងភ្លាត់ពុំបានទារយោបបណ្តាលមកអំពីការប្រព្រឹត្តនៃអ្នកជាប់ពន្ធអាករក្តី បណ្តាលមកពីការភ័ន្តច្រឡំនៃភ្នាក់ងារពន្ធក្តី ក្នុងកំឡុង ៣ ឆ្នាំ គិតចាប់ពីឆ្នាំដែលគិតយកពន្ធអាករ ។

ប៉ុន្តែបើមានការវិវាទឡើងដល់តុលាការហើយរកទៅឃើញថា អ្នកជាប់ពន្ធអាករពុំបានបង់ពន្ធអាករ ឬបង់ពុំគ្រប់គ្រាន់តាមកំរិតនោះ អង្គការពន្ធអាចទារអោយបង់រហូតដល់ពេលដាច់ឆ្នាំ ដែលជាឆ្នាំបន្ទាប់ពីឆ្នាំកាត់សេចក្តី ។

មាត្រា៦២ .. ជនណាដែលបានញុះញង់អ្នកជាប់ពន្ធអាករម្នាក់ ឬ ច្រើននាក់អោយបដិសេធ ឬ ពន្យារការបង់ពន្ធអាករតាមការបំពានលើរូបរាងកាយ តាមការគំរាមកំហែង ឬ តាមការរៀបចំឧបាយកល សំដៅរាំងស្ទះការកំណត់មូលដ្ឋានគិតពន្ធអាករ ឬ ការយកពន្ធអាករ ត្រូវទទួលទោសជាប់គុកពី ៦ ខែទៅ ៣ ឆ្នាំ ។

មាត្រា៦៣ .. មន្ត្រី និង ភ្នាក់ងារពន្ធដារដែលបន្លំលួច កែបំបាត់ ប្រាក់ពន្ធអាករ ប្រាក់ពិន័យ ទារសំណូក អ្នកសួក និង អ្នកកណ្តាលក្នុងបទសូក ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

មាត្រា៦៤ .. ក្រឹត្យច្បាប់លេខ ២៣ ក្រច ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៨៥ ស្តីពីពន្ធអាជីវកម្ម និង បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៦៥ .. ច្បាប់ត្រូវប្រកាសជាការប្រញាប់ ។

ច្បាប់នេះត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័ត
នៅថ្ងៃ ទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ នាសម័យប្រជុំ រដ្ឋសភា លើកទី ១
នីតិកាលទី ១ ។

ភ្នំពេញ , ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

ប្រធានរដ្ឋសភាស្តីទី



សឺន_សូប៊ែរ្ត៍

# តារាង "ខ"

## ចំនួនបុគ្គលិកពិតរបស់ក្រសួងនានា

បូកសរុបតាមក្រសួង

| ក្រសួងនានា | សរុប បុគ្គលិកអចិន្ត្រៃយ៍ | រដ្ឋបាលកណ្តាល | | | | | | ខេត្តនានា |
|---|---|---|---|---|---|---|---|---|
| | | បុគ្គលិកអចិន្ត្រៃយ៍ | | | | | បុគ្គលិកអណ្តែត | |
| | | សរុប | ប្រភេទ "ក" | ប្រភេទ "ខ" | ប្រភេទ "គ" | នានា | ចំនួនសរុបមិនបៀវត្សទាំងអស់ "លាគ្មានបៀវត្ស" | ចំនួនពិតបុគ្គលិកអចិន្ត្រៃយ៍ |
| ១២_ក្រសួងអប់រំយុវជននិងកីឡា | 74 921 | 2 861 | 202 | 2 041 | 618 | | 41 | 72 060 |
| ១_អប់រំ | 73 276 | 1 216 | 85 | 888 | 243 | | 5 | 72 060 |
| ២_ឧត្តមសិក្សា | 1 185 | 1 185 | 40 | 958 | 187 | | 6 | |
| ៣_យុវជននិងកីឡា | 460 | 460 | 77 | 195 | 188 | | 30 | |
| ១៣_ក្រសួងពាណិជ្ជកម្ម | 2 072 | 587 | 116 | 314 | 83 | 74 | | 1 485 |
| ១៤_ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល | 2 416 | 558 | 102 | 397 | 59 | | | 1 858 |
| ១៥_ក្រសួងផែនការ | 1 485 | 354 | 94 | 207 | 53 | | 4 | 1 131 |
| ១៦_ក្រសួងសុខាភិបាល | 18 797 | 5 953 | 159 | 3 284 | 743 | 1 767 | | 12 844 |
| ១៧_ក្រសួងទេសចរណ៍ | 395 | 250 | 47 | 119 | 74 | 10 | 3 | 145 |
| ១៨_ក្រសួងធម្មការនិងកិច្ចការសាសនា | 579 | 200 | 35 | 30 | 135 | | 3 | 379 |
| ១៩_ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | 2 208 | 1 524 | 97 | 1 057 | 370 | | 5 | 684 |
| ២០_ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | 2 657 | 1 658 | 192 | 985 | 481 | | 50 | 999 |
| ២១_ក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន | 2 185 | 650 | 86 | 399 | 165 | | 4 | 1 535 |

ប្រភេទ "ក": បុគ្គលិកក្របខ័ណ្ឌដែលស្ថាប័នសាធារណៈ

